# CAMBODIA



ចំនួនប្រជាជន 14,9 លាននាក់

កំនើនប្រជាជន 1,8 ភាគរយ

ផសស (PPP, int'l US$) 37,1ពាន់លាន

ផសសក្នុងពលរដ្ឋម្នាក់ (PPP, int'l US$) 2,494

ផ្ទៃដី 181,040 គីឡូម៉ែតការ៉េ

រាជធានី ភ្នំពេញ

Source: World Development Indicators.

## ខ្លឹមសារសង្ខេប

សេដ្ឋកិច្ចកម្ពុជានៅតែរឹងមាំ ក្នុងពេលបរិយាកាសសេដ្ឋកិច្ចពិភពលោកកំពុងប្រឈមនឹងបញ្ហា និងលទ្ធភាពសំរេចបានតាមការព្យាករកំណើនប្រមាណ 7 ភាគរយនៅឆ្នាំ2013 ទំនងជាមានលក្ខណ:អំណោយផល។ ទស្សនវិស័យនៅតែវិជ្ជមានដោយកំណើនខ្លាំង និងមាននិរន្តរភាព នៃវិស័យកសិកម្ម ជាមួយអាកាសធាតុអំណោយផល ការនាំចេញសម្លៀកបំពាក់ សកម្មភាពរីកចំរើនឡើងវិញ នៃវិស័យ សំណង់ និងការរីកចំរើនដ៏ខ្លាំងនៃវិស័យទេសចរណ៍។ ទស្សនវិស័យប្រឈមនឹងហានិភ័យមួយចំនួន។ គេនៅមិនទាន់ដឹងច្បាស់នៅឡើយទេអំពីទំហំនៃផលប៉ះពាល់នៃភាពមិនប្រាកដប្រជាផ្នែក នយោបាយក្រោយពេលបោះឆ្នោត មកលើការវិនិយោគផ្ទាល់ពីបរទេស និងកំណើនទោះបីជាកត្តាពីរខាងក្រៅប្រសើរជាងមុន ដោយមានសញ្ញាល្អខ្លះៗនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក និងសហគមអឺរ៉ុប។

## ការរីកចំរើនសេដ្ឋកិច្ចពេលថ្មីៗ

សេដ្ឋកិច្ចកម្ពុជានៅតែរឹងមាំ ក្នុងពេលបរិយាកាសសេដ្ឋកិច្ចពិភពលោក កំពុងប្រឈមនឹងបញ្ហា។ កំណើនផលិតផលក្នុងស្រុកសរុបពិតស្មើនឹង 7,3 ភាគរយ នៅឆ្នាំ 2012 និងរំពឹងថាកំណើនប្រហែល ៧ភាគរយនៅឆ្នាំ 2013។ កំណើនផលិតផលក្នុងស្រុកសរុបត្រូវបានជំរុញ ដោយកំណើនខ្លាំងនិងមាននិរន្តរភាពនៃវិស័យកសិកម្ម ការនាំចេញសម្លៀកបំពាក់ សកម្មភាពរីកចំរើនឡើងវិញនៃវិស័យសំណង់ និងការរីកចំរើនដ៏ខ្លាំងនៃវិស័យទេសចរណ៍។

ការសម្របខ្លួនទៅនឹង ការផ្លាស់ប្តូរនៅក្នុងទីផ្សារគោលដៅចំពោះ ការនាំចេញសម្លៀកបំពាក់ ការពង្រីកផ្ទៃដីដាំដុះ និងពិពិធកម្មប្រភពនៃវិស័យទេសចរណ៍ បានជួយដល់ក្បាលម៉ាស៊ីនសេដ្ឋកិច្ចសំខាន់ៗ បី របស់កម្ពុជា អោយធានាបាននូវចលករជំរុញអោយមានកំណើនផលិតផលក្នុងស្រុកសរុប (ផសស)។ ការនាំចេញសម្លៀកបំពាក់បានសំរបខ្លួននឹងលក្ខខ័ណ្ឌទីផ្សារនាំចេញ ដោយផ្តោតលើ សម្លៀកបំពាក់តំលៃថោក សំរាប់ទីផ្សារសហរដ្ឋអាមេរិក និងសម្លៀកបំពាក់តំលៃថ្លៃសំរាប់ទីផ្សារសហគមអឺរ៉ុប។ ក្នុងវិស័យ កសិកម្ម ការកើនឡើងខ្ពស់នៃផលិតកម្មស្រូវកំពុងបន្ត។ ការកើនឡើងខ្ពស់នៃផ្ទៃដីដាំដុះដំណាំស្រូវ (ដោយការកើនឡើងផ្ទៃដី និងការស្រោចស្រព) រួមចំណែកប្រមាណ 80 ភាគរយនៃកំណើនផលិតផលស្រូវប្រចាំឆ្នាំក្នុងរយះពេល 4 ឆ្នាំកន្លងមក។ ពិពិធកម្មប្រកបដោយជោគជ័យនៃទីផ្សារទេសចរណ៍ទាក់ទាញបានអ្នកទេសចរណ៍មកពីអឺរ៉ុបខាងកើត អាស៊ី ខាងកើត នឹងតំបន់ប៉ាស៊ីហ្វិក ធ្វើអោយវិស័យទេសចរ បន្តការកើនឡើងខ្ពស់។ គិតត្រឹមខែមិថុនា ឆ្នាំ 2013 ការនាំចេញ សម្លៀកបំពាក់បានកើនឡើង 18 ភាគរយ បើប្រៀបធៀបនឹង រយះពេលដូចគ្នាក្នុងឆ្នាំ 2012 ចំនែកវិស័យទេសចរណ៍វិញបន្តមាននិន្នាការរីកចម្រើនខ្ពស់ ការមកដល់នៃភ្ញៀវទេសចរបានកើនដល់ 19 ភាគរយ។

ជាលទ្ធផលនៃល្បឿន និងនិន្នាការនៃកំណើនឆាប់រហ័សដែលផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនមួយភាគធំ ភាពក្រីក្រនៅប្រទេសកម្ពុជាបានធ្លាក់ចុះយ៉ាងខ្លាំង។ កំណើនសេដ្ឋកិច្ចដែលរីករាលដាលក្នុងរយ:ពេលប៉ុន្មានឆ្នាំកន្លងទៅ មួយផ្នែកធំដោយ សារកំណើនប្រកបដោយចីរភាពក្នុងវិស័យកសិកម្ម ដែលអំណោយផលដោយកំណើនថ្លៃអង្ករនៅទីផ្សារសកលលោក។ ភាគរយនៃចំនួនប្រជាជនក្រីក្រ ត្រូវបានកាត់បន្ថយច្រើនជាងពាក់កណ្តាលក្នុងរយ:ពេលប្រាំពីរឆ្នាំ ចុះមកត្រឹមប្រមាណជា 20 ភាគរយ នៅឆ្នាំ 2011 ។ បើទោះបីជាការកាត់បន្ថយភាពក្រីក្រមានទំហំធំក្តី គ្រួសារភាគច្រើនដែលបានចាកផុតពីភាពក្រីក្រ នៅមានគំលាតតិចតួចពីភាពក្រីក្រ មានន័យថាគ្រួសារទាំងនោះបានផ្លាស់ប្តូរពីគ្រួសារក្រីក្រ ទៅជាគ្រួសារដែលមានជីវភាពជិតក្រីក្រ។

ឱនភាពគណនីចរន្ត (មិនរួមបញ្ចូលប្រាក់បង្វែរផ្ទេរការ) មានប្រហែល 10,1 ភាគរយនៃផលិតផលក្នុងស្រុកសរុបឆ្នាំ 2012 បើប្រៀបធៀបជាមួយឆ្នាំ2011ដែលមានតែ 7,9 ភាគរយ នៃផលិតផលក្នុងស្រុក។ ការកើនឡើងនៃការនាំចូលប្រេងឥន្ធនៈ យានយន្ត និង សំភារៈសំណង់ ធ្វើអោយការនាំចូលសរុបកើនឡើងក្នុងឆ្នាំ 2012។ ឧនភាពគណនីចរន្តធំដែលប្រទេសកម្ពុជាមាននេះគឺ ជួយអោយមាន ការនាំចូលសំរាប់គំរូវការ វិនិយោគ។ អតិរេកគណនីមូលធន និងហិរញ្ញវត្ថុបានកើនឡើងខ្លាំងដោយសារការកើនឡើងនៃវិនិយោគផ្តល់ពីបរទេសដល់កំរិតកំពូល 1,4 ពាន់លានដុល្លាអាមេរិកក្នុងឆ្នាំ2012។ វិនិយោគផ្ទាល់ពីបរទេសបានកើនឡើងនៅពាក់កណ្តាលទីមួយ ឆ្នាំ2013 ហើយវិនិយោគិន នៅតែមានការចាប់អារម្មណ៍ខ្លាំង ក្នុងការវិនិយោគអំឡុងពេលបោះឆ្នោតនេះ ខុសពីការបោះឆ្នោតកាលពីពេលមុនៗ ។

ដោយសារតែអតិរេកគណនីមូលធន សមតុល្យជញ្ជីងទូទាត់នៅតែវិជ្ជមាន ហើយទុនបំរុងអន្តរជាតិបានកើនឡើង។ ទុនបំរុងអន្តរជាតិកើនដល់ 3,5 ពាន់លានដុល្លារសហរដ្ឋអាមេរិក ឬ 3,7 ខែ នៃតំលៃនៃការនាំចូលសរុបក្នុងឆ្នាំ2012 ប្រៀបធ្រៀបនឹង 3,0 ពាន់លានដុល្លារសហរដ្ឋអាមេរិក ឬ 3,4 ខែ តំនៃតំលៃនៃការនាំចូលសរុប ឆ្នាំ 2011។ គិតត្រឹមខែមិថុនា ឆ្នាំ 2013 នេះ ទុនបម្រុងអន្តរជាតិដុលបានកើនដល់ 3.6 ពាន់លានដុល្លារអាមេរិក ។

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) បានធ្លាក់ចុះដល់ 2,5 ភាគរយនៅចុង ឆ្នាំ 2012 ធៀបនឹង 4,9 ភាគរយ នៅឆ្នាំ 2011 ដោយសារតែស្ថេរភាពថ្លៃនៃប្រភេទផលិត ផលសំខាន់ៗ ពិសេស ថ្លៃស្បៀងអាហារ ដែលមានទំងន់ស្មើនឹង 43 ភាគរយ នៃកញ្ចប់អតិផរណា។ នៅក្នុងខែមិថុនាឆ្នាំ 2013 ឆ្នាំ អតិផរណាពីមួយឆ្នាំទៅមួយឆ្នាំបានកើនឡើងដល់ 2,9 ភាគរយ ដោយសារតែការកើនឡើងបន្តិចនូវថ្លៃស្បៀងអាហារ ។ អតិផរណាត្រូវបានគេប៉ាន់ស្មានថាមានកម្រិតទាបត្រឹមតួលេខមួយខ្ទង់ ក្នុងដំណាក់កាលខ្លី។

អត្រាប្តូរប្រាក់នៅតែមានស្ថេរភាព ការអភិវឌ្ឍស៊ីជំរៅ ផ្នែកហិរញ្ញវត្ថុប្រព្រឹត្តទៅជាបន្ត។ ប្រាក់រៀលត្រូវបានភ្ជាប់ជាមួយប្រាក់ដុល្លារអាមេរិក ចំណែកអត្រាប្តូរប្រាក់វិញបាននឹងកំពុងនៅទ្រឹងជុំវិញ 4,000 រៀល ក្នុងមួយដុល្លារ។ អត្រាប្តូរប្រាក់ធ្លាក់ថ្លៃបន្តិចហើយប្រាក់រៀលចុះថោកដល់ 4,062 រៀល ក្នុងមួយដុល្លារអាមេរិកក្នុងខែមិថុនា ឆ្នាំ 2013[1] ។ ការអភិវឌ្ឍស៊ីជំរៅផ្នែកហិរញ្ញវត្ថុនៅបន្ត ចំនួនធនាគារដែលចូលទីផ្សារកម្ពុជាមានការកើនឡើង។ ការប្រកួតប្រជែងរវាងធនាគារបានរួមចំណែកដល់ការកាត់បន្ថយ គម្លាត រវាងអត្រាការប្រាក់អោយខ្ចី និងអត្រាការប្រាក់បញ្ញើរជាដុល្លារអាមេរិក និងជំរុញ អោយមានប្រសិទ្ធិភាពខ្លះៗនៅក្នុងទីផ្សារ។ ទោះជាយ៉ាងណាក្តី ហានិភ័យកើនឡើងនៅពេលមានចំនួនធនាគារច្រើន ដោយសារតែមានបញ្ហាប្រឈមលើ សមត្ថភាពត្រួតពិនិត្យ ។ កំណើនថ្មីៗនៃការផ្តល់ឥណទានកើនដល់ 30ភាគរយ ប្រៀបធៀបនឹងឆ្នាំមុនផ្តល់ប្រយោជន៍ដល់វិស័យកសិកម្មដែលទទួលបានប្រហែល 570 លានដុល្លាអាមេរិក ឬ 10 ភាគរយនៃឥណទានសរុបនៅដំណាច់ឆ្នាំ 2012 ប្រៀបធៀប នឹង 100 លានដុល្លាអាមេរិក ឬ 5 ភាគរយ នៃឥណទានសរុបនៅដំណាច់ឆ្នាំ 2008។

ក្នុងកំឡុងពេលប្រាំខែដំបូងនៃឆ្នាំ 2013 ចំណូលក្នុងស្រុកនៅតែកើនឡើងប៉ុន្តែមានកំណើនយឺតពោលគឺកើនឡើងត្រឹមតែ 9,6 ភាគរយ ពីមួយឆ្នាំទៅមួយឆ្នាំ ធៀបនឹង 24,7 ភាគរយនៅឆ្នាំ 2012[2] ។ ទោះជាយ៉ាងណាក្តី ចំណាយសាធារណៈហាក់មានល្បឿនយឺត ។ ដូច្នេះ ឱនភាពថវិកា (មិនរួមបញ្ចូលជំនួយឥតសំណង) គួរតែអនុវត្តបានដូចការគ្រោងទុកក្នុងថវិកាជុំវិញ 5,4 ភាគរយនៃផលិតផលក្នុងស្រុកសរុប។ ការគ្រប់គ្រងសារពើពន្ធនៅតែមានភាពសមស្រប និងគាំទ្រ ដល់ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ប៉ុន្តែនៅមានលទ្ធភាពច្រើន សម្រាប់បង្កើនប្រាក់ចំណូលក្នុងស្រុក និងសម្រាប់បង្កើនប្រសិទ្ធភាពចំណាយ ។ នៅឆ្នាំ 2012 ប្រទេស កម្ពុជាបានស្តារឡើងវិញនូវលំហសារពើពន្ធដោយសារការកើនឡើងខ្ពស់ នៃចំនូលក្នុងស្រុក ដែលត្រូវបានប៉ាន់ស្មានថានឹងឡើងដល់ 14,4 ភាគរយ នៃ ផលិតផលក្នុងស្រុកសរុប ក្នុងឆ្នាំ 2012 ធៀបទៅនឹង 13,1 ភាគរយនៅក្នុង ឆ្នាំ 2011។ ទោះជាយ៉ាងណាក្តីរដ្ឋាភិបាលបន្តពឹងផ្អែកយ៉ាងខ្លាំង លើម្ចាស់ជំនួយ ដែលផ្តល់មូលនិធិជិតស្មើនឹង 80 ភាគរយ នៃការវិនិយោគសាធារណៈសរុប ឬត្រូវជា 34 ភាគរយនៃចំណាយសាធារណៈសរុប។

**ទស្សនវិស័យ និងភាពប្រឈមដែលកំពុងលេចរូបរាងឡើង**

ទស្សនវិស័យផ្នែកម៉ាក្រូសេដ្ឋកិច្ចជាទូទៅនៅតែវិជ្ជមាន ដោយកំណើនខ្លាំង និងមាននិរន្តរភាពនៃវិស័យកសិកម្ម ជាមួយ លក្ខខ័ណ្ឌ អាកាសធាតុអំណោយផលការនាំចេញដែលមិនស្រុត និងការរីកចំរើនដ៏ខ្លាំងនៃវិស័យទេសចរណ៍។ ទស្សនវិស័យប្រឈមនឹងហានិភ័យមួយចំនួន។ គេនៅមិនទាន់ដឹងច្បាស់នៅឡើយទេអំពីទំហំនៃផលប៉ះពាល់នៃភាពមិនប្រាកដប្រជាផ្នែកនយោបាយក្រោយពេលបោះឆ្នោត មកលើការវិនិយោគផ្ទាល់ពីបរទេស និងកំណើនទោះបីជាមានការប្រសើរឡើងខ្លះៗនៃកត្តាខាងក្រៅ។ ដូច្នេះហើយការព្យាករណ៍កំណើនសេដ្ឋកិច្ចសំរាប់ឆ្នាំ 2014 ត្រូវបានរក្សាប្រមាណ 7ភាគរយ ដូចឆ្នាំ 2013 ដែរ។

ទស្សនវិស័យអំពីនិរន្តរភាពជារួមនៃបំណុលនៅតែមានលក្ខណៈអំណោយផល ។ ការវិភាគនិរន្តរភាពបំណុល (DSA) ឆ្នាំ 2012 រួមគ្នារវាងធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិបង្ហាញថា ចំណាត់ថ្នាក់លើភាពពិបាកសងបំណុលរបស់ប្រទេសកម្ពុជានៅតែមានកម្រិតទាប។ គោលនយោបាយរបស់ រដ្ឋាភិបាល ក្នុងការជៀសវាងកម្ចីមិនមែនសម្បទាន គឺជាកត្តាសំខាន់ចំពោះការគ្រប់គ្រង បំណុលប្រកបដោយនិរន្តរភាព។ ទំហំបំណុលសាធារណៈក្រៅប្រទេសរបស់កម្ពុជា និងបំណុលធានាដោយវិស័យ សាធារណៈមានប្រមាណជា 30,1 ភាគរយនៃផលិតផលក្នុងស្រុកសរុប ក្នុងទំហំទឹកប្រាក់ជាក់ស្តែងនៅបំណាច់ឆ្នាំ 2012 ។

---

[1] អត្រាប្តូរប្រាក់ផ្លូវការមធ្យម

[2] តួលេខសារពើពន្ធបឋមសម្រាប់ឆ្នាំ2013

## ប្រទេសកម្ពុជា: សូចនករណ៍សំខាន់ៗ

| | 2012 | 2012 | 2013 f | 2014f | 2015f |
|---|---|---|---|---|---|
| | Year | Year | Year | Year | Year |
| **លទ្ធផល ការងារ និងថ្លៃ** | | | | | |
| ផសស ពិត (%ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | 7.1 | 7.3 | 7.0 | 7.0 | 7.0 |
| តម្រូវការក្នុងស្រុក (%ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | 1.0 | 11.9 | 9.0 | 8.3 | 8.7 |
| សន្ទស្សន៍ផលិតកម្មឧស្សាហកម្ម (2000=100) | 300.8 | 315.9 | 341.1 | 363.3 | 388.7 |
| (%ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | 14.5 | 5.0 | 8.0 | 7.0 | 7.0 |
| សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (%ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | 4.9 | 2.5 | 5.0 | 6.0 | 5.0 |
| **វិស័យសាធារណៈ** | | | | | |
| ចំណូលរដ្ឋាភិបាល (% នៃ ផសស) | 13.2 | 14.4 | 14.2 | 14.5 | 14.8 |
| ចំណាយរដ្ឋាភិបាល (% នៃ ផសស) | 22.8 | 19.7 | 19.6 | 20.0 | 19.0 |
| តុល្យការរដ្ឋាភិបាល (% នៃ ផសស) | -9.6 | -5.3 | -5.4 | -5.5 | -4.2 |
| **វិពាណិជ្ជកម្មក្រៅប្រទេស ជញ្ជីងទូទាត់ និង បំណុលបរទេស** | | | | | |
| ជញ្ជីងវិពាណិជ្ជកម្ម (លានដុល្លារអាមេរិក) | -1,490 | -1,949.2 | -2,082.3 | -2,636.8 | -2,956.1 |
| ទំនិញនាំចេញ (លានដុល្លារអាមេរិក) | 5,220 | 6,015.7 | 6,918.1 | 7,713.6 | 9,102.1 |
| (%ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | 34.4 | 11.4 | 15.0 | 11.5 | 18.0 |
| ទំនិញនាំចេញសំខាន់ៗ (%ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ)1/ | 31.7 | 7.0 | 18.0 | 15.5 | 20.0 |
| ទំនិញនាំចូល (លានដុល្លារអាមេរិក) | 6,710 | 7,964.9 | 9,000.3 | 10,350.4 | 12,058.2 |
| (%ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | 22.7 | 18.7 | 13.0 | 15.0 | 16.5 |
| សមតុល្យគណនីចរន្ត (លានដុល្លារអាមេរិក) 2/ | -1,015 | -1,436.6 | -1,499.2 | -2,065.7 | -2,217.1 |
| (% នៃ ផសស) | -7.9 | -10.1 | -9.6 | -12.0 | -11.8 |
| ការវិនិយោគផ្ទាល់ពីបរទេស (លានដុល្លារអាមេរិក) 3/ | 785 | 1,410.2 | 1,452.5 | 1,626.8 | 1,748.8 |
| បំណុលបរទេស (លានដុល្លារអាមេរិក) | 3,611 | 4,281.0 | 4,726.0 | 5,229.5 | 5,634.1 |
| (% នៃ ផសស) | 28.1 | 30.2 | 30.2 | 30.4 | 29.9 |
| បំណុលរយៈពេលខ្លី (លានដុល្លារអាមេរិក) | 66.8 | 67.0 | 66.9 | 66.7 | 66.5 |
| អនុបាតសេវាបំណុល(% នាំចេញទំនិញនិងសេវាកម្ម) | 1.2 | 1.2 | 1.3 | 1.5 | 1.5 |
| ប្រាក់បំរុងបរទេសដុល (លានដុល្លារអាមេរិក) | 3,032 | 3,463.0 | 3,843.9 | 4,151.4 | 4,525.1 |
| (ចំនួនខែនាំចូលទំនិញនិងសេវាកម្ម) | 3.4 | 3.3 | 3.2 | 3.1 | 3.0 |
| **វិទីផ្សារហិរញ្ញវត្ថុ** | | | | | |
| ឥណទានក្នុងស្រុក (%ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | 37.7 | 34.0 | 28.0 | 25.0 | 25.0 |
| អត្រាប្តូរប្រាក់រយៈពេលខ្លី (ក្នុងមួយឆ្នាំ) | 15.0 | 13.7 | 13.0 | 13.5 | 13.5 |
| អត្រាប្តូរប្រាក់ (រៀល/ដុល្លាអាមេរិកចុងគ្រា) | 4,039.0 | 3,995.0 | 4,000.0 | 4,063.6 | 4,076.0 |
| អត្រាប្តូរប្រាក់ប្រសិទ្ធ (2000=100) | 124.8 | 128.6 | .. | .. | .. |
| (%ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | 1.9 | 3.0 | .. | .. | .. |
| កំណត់ចំណាំ:ផសស ជាក់ស្តែង (គិតជាលានដុល្លារអាមេរិក) | 12,828 | 14,195.6 | 15,649.0 | 17,213.9 | 18,844.5 |

ប្រភព: សមត្ថកិច្ចរដ្ឋាភិបាល មូលនិធិរូបិយបណ្ណអន្តរជាតិ និងការប៉ាន់ស្មានរបស់ធនាគារពិភពលោក

e = ប៉ាន់ស្មាន

f = ព្យាករណ៍

1/ សម្លៀកបំពាក់

2/ មិនរួមបញ្ចូលប្រាក់បង្វែរផ្លូវការ

3/ ចាប់ពីឆ្នាំ 2011គិតទាំងវិនិយោគដោយផ្ទាល់ពីបរទេសដែលទាក់ទងជាមួយគំរោងវិស័យតាមពលរដ្ឋ និងឯកជន